# សុន្ទរកថារបស់**លោក ភាខ៉ាមូរ៉ា ហ៊ីរ៉ូស៊ី** ភារធារីស្តីទីស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

០២ មិនា ២០១២

**សូមគោរព លោក ជា ជាតិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមា នសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ សម្រាប់គម្រោងសាងសង់សាលាបឋមសិក្សាព្រែកព្នៅ។

ខ្ញុំជឿជាក់ថា ការអប់រំ និងការអភិវឌ្ឍន៍ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ការអប់រំ និង ការអភិវឌ្ឍន៍ធនធានមនុស្ស ដោយចាត់ទុកជាមុំមួយនៃបណ្តាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណសម្រាប់អភិវឌ្ឍន៍ជាតិរបស់ខ្លួន។ ដោយអនុលោមតាមគោលការណ៍នេះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភដល់វិស័យអប់រំទាំងផ្នែកសម្ភារៈ និងបច្ចេកទេស។

ជំនួយឧបត្ថម្ភដែលផ្តល់ជូន មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ នាថ្ងៃនេះគឺដើម្បីសាងសង់អគារសិក្សាថ្មីធ្វើអំពីបេតុងមួយខ្នងមាន៧បន្ទប់ និងបរិក្ខារអនាម័យនៅ សាលាបឋមសិក្សាព្រែកព្នៅស្ថិតក្នុងរាជធានីភ្នំពេញ។ យើងបានកត់សម្គាល់ឃើញថាដោយសារមានបញ្ហាកង្វះបន្ទប់សិក្សា ថ្នាក់រៀន៩ ក្នុងចំណោមថ្នាក់រៀន៣២ត្រូវខ្ចីបន្ទប់សិក្សាពីអនុវិទ្យាល័យដែលនៅក្បែរនោះ។ តាមរយៈគម្រោងនេះ កុមារាកុមារីជាង១,១០០នាក់នឹងអាចសិក្សានៅក្នុងបន្ទប់សិក្សារបស់ពួកគេផ្ទាល់។

ខ្ញុំសង្ឃឹមថា សិស្សានុសិស្សក្នុង សាលាបឋមសិក្សាព្រែកព្នៅនឹងអាចសិក្សាប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិស្ថានអប់រំកាន់តែប្រសើរឡើង។ ដូច្នេះហើយ ខ្ញុំសូមសំណូមពរឲ្យសិស្សានុសិស្សទាំងអស់ថែរក្សាសាលារៀនឲ្យបានស្អាត និងត្រឹមត្រូវសម្រាប់ពួកគេផ្ទាល់ក៏ដូចជាសម្រាប់កុមារដែលនឹងត្រូវមកសិក្សានៅសាលានេះនាពេលអនាគត។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណ!